# ផែនការសម្រាប់រយៈពេលដែលនៅសល់នៃឆ្នាំសិក្សាឆ្នាំនេះ រដូវក្តៅ និងឆ្នាំសិក្សាឆ្នាំក្រោយ

ក្រសួងអប់រំឡុងប៊ីច LBUSD បន្តសហការជាមួយការិយាល័យអប់រំនៃខោនធីឡូសអិនជេលេស Los Angeles County Office of Education ក្រសួងសុខាភិបាលនិងធនធានមនុស្សនៃក្រុងឡុងប៊ីច ហើយនិងអង្គការផ្សេងៗនៅក្នុងតំបន់និងនៅក្នុងរដ្ឋ ដើម្បីការពារសុខភាពនិងសុវត្ថិភាពរបស់សិស្ស ក្រុមគ្រួសាររបស់ពួកគេ និងបុគ្គលិកសាលារៀន នៅក្នុងពេលរាតត្បាតជាបន្តទូទាំងពិភពលោកនៃរោគកូរ៉ូណា។

## ការរៀនចប់ពីវិទ្យាល័យ និងការបញ្ចប់ឆ្នាំសិក្សា

ដោយសារតែមន្ត្រីសុខភាពបន្តផ្តល់ឱវាទឱ្យជៀសវាងការជួបប្រជុំគ្នាជាក្រុមធំៗ ជាការសោកស្តាយណាស់ដែលសាលារៀនមិនអាចធ្វើពិធីអបអរដល់ការបញ្ចប់ការសិក្សាពីសាលាវិទ្យាល័យតាមធម្មតា ឬពិធីអបអរការឡើងថ្នាក់ កម្រិតមត្តេយ្យដល់ទី ៨ (K-8) ។ ក៏ប៉ុន្តែក្រសួងអប់រំកំពុងតែធ្វើការយ៉ាងមមារញឹកដើម្បីធ្វើពិធីអបអរដល់ការសិក្សាចប់ពីវិទ្យាល័យតាមរយៈអនឡាញដ៏គួរឱ្យចងចាំមួយ។ ព័ត៌មានបន្ថែមអំពីពិធីអបអរការសិក្សាចប់ពីវិទ្យាល័យតាមរយៈអនឡាញហើយនិងការបញ្ចប់ការសិក្សានៅឆ្នាំនេះនឹងមានផ្តល់ឱ្យក្រុមគ្រួសារសិស្សនិងបុគ្គលិកសាលានៅក្នុងពេលឆាប់ៗខាងមុខនេះ។

## កាសិក្សាក្នុងរដូវក្តៅនិងកម្មវិធីផ្សេងៗទៀតនៅក្នុងរដូវក្តៅ

នៅក្នុងខែនៃរដូវក្តៅ ក្រសួងអប់រំនឹងមានផ្តល់យ៉ាងតិចតួចនូវសកម្មភាពជួបគ្នាផ្ទាល់ យោងតាមការណែនាំរបស់អង្គការសុខភាពនានាដែលយើងធ្វើការជាមួយ។ សកម្មភាពទាំងនេះគឺសម្រាប់តែអ្នកធ្វើការសំខាន់ៗ អ្នកមើលថែកុមារ កម្មវិធីព្រីស្គូលតូចៗ និងកម្មវិធីជំនួយផ្តល់អន្តរាគមផ្ទាល់ខ្លួនខ្លះៗដល់សិស្សណាដែលត្រូវការជំនួយបន្ថែម។ សូមរំឭកអំពីសេវាមើលថែកុមារដែលមានក្នុងបច្ចុប្បន្ននេះ - អង្គការមិនយកប្រាក់ចំណេញ Pacific Gateway Workforce Partnership មានកម្មវិធី [WorkLB](), ដែលជាសេវាតាមរយៈអនឡាញមិនគិតថ្លៃឈ្នួលសម្រាប់ភ្ជាប់អ្នកមើលថែកុមារជាមួយមាតាបិតាណាដែលត្រូវការអ្នកមើលថែកូនជាបន្ទាន់។ ដើម្បីព័ត៌មានបន្ថែមសូមទាក់ទងទៅលេខ (562) 570-4249.

នៅក្នុងរដូវក្តៅ យើងនឹងមិនអាចផ្តល់សកម្មភាពកីឡាឬការជួបជុំសិស្សឬបុគ្គលិកសាលាដែលមានគ្នាច្រើនបានទេ រហូតដល់មានដំណឹងថ្មី។ ក្រសួងអប់រំនឹងផ្តល់ការសិក្សាក្នុងរដូវក្តៅតាមរយៈអនឡាញសម្រាប់ថ្នាក់ទី៩-១២ ចាប់ផ្តើមឡើងបន្ទាប់ពីការបញ្ចប់ឆ្នាំសិក្សាធម្មតា ហើយកំពុងគិតគូរបន្ថែមកម្មវិធីអន្តរាគមផ្សេងៗទៀត។ ព័ត៌មានបន្ថែមទៀតនឹងមានផ្តល់ឱយជាបន្តបន្ទាប់។

## ការចាប់ផ្តើមឆ្នាំសិក្សា 2020-21

ប្រតិទិនសម្រាប់ឆ្នាំសិក្សា 2020-21 នឹងចាប់ផ្តើមនៅថ្ងៃទី១ ខែកញ្ញា ហើយចប់នៅថ្ងៃទី១៦ខែមិថុនា 2021។ ក្រសួងអប់រំឡុងប៊ីច LBUSD បន្តរៀបចំផែនការសម្រាប់ឆ្នាំសិក្សាថ្មី ដែលនឹងមានជំរើសជាច្រើនសម្រាប់សិស្ស។ ថ្ងៃចាប់ផ្តើមឆ្នាំសិក្សាថ្មីដែលបានគ្រោងទុកមកគឺនៅដដែល ក៏ប៉ុន្តែ ឆ្នាំសិក្សាថ្មី នឹងមិនមានសភាពដូចធម្មតាទេ ដែលចាំបាច់តម្រូវឱ្យក្រសួងអប់រំគិតគូររកមើលការកែសម្រួលផ្សេងៗ។ នៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខនេះ គ្រួសារសិស្សនឹងបានទទួលតំណ Link សម្រាប់ការស្ទង់មតិដើម្បីប្រមូលមតិឬយោបល់ផ្សេងៗអំពីកម្មវិធីសិក្សានៅផ្ទះបច្ចុប្បន្ន ហើយសម្រាប់ជួយរៀបចំផែនការសម្រាប់ឆមាសនៅរដូវឈើជ្រុះស្លឹកខាងមុខនេះ។

## ព័ត៌មាននិងធនធានបន្ថែមទៀត

រកមើលព័ត៌មាននិងធនធានបន្ថែមទៀតនៅគេហទំព័រ [Coronavirus Response website]() របស់ក្រសួងអប់រំនៅ lbschools.net ។